## ១២. អនុសាសន៍

យោងលើសេចក្តីសន្និដ្ឋានស្តីពីហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ក្រុមការងារសូមផ្តល់នូវអនុសាសន៍ និងវិធានការមួយចំនួនដូចខាងក្រោម:

**១៨៥.** មុនពេលស្នើសុំដំណើរអាជីវកម្មរ៉ែ ក្រុមហ៊ុន **Samnang Rea Thborng Thmor Import-Export and Development Co., Ltd.** ត្រូវរៀបចំផែនម្ម ដោយក្នុងនោះត្រូវបញ្ជាក់អំពីផែនការផលិតកម្ម អោយត្រឹមត្រូវច្បាស់លាស់តាមបទដ្ឋានបច្ចេកទេសអាជីវកម្មរ៉ែ។ ទន្ទឹមនឹងនេះក្រុមហ៊ុនត្រូវស្វែងរកដៃគូរអាជីវករ (ឧស្សាហ៍ករ) អោយបានបន្ថែមដើម្បីពង្រីកលទ្ធភាពអាជីវកម្ម អោយសមស្របតាមស្ថានភាពជំរកនិងសន្និធិរបស់រ៉ែក្នុងតំបន់នោះ។ ក្រុមហ៊ុនត្រូវបង្ហាញអំពីសមត្ថភាពជាក់ស្តែងនៅក្នុងផលិតកម្មរ៉ែសរុបតិចបំផុតពី ១៥-២០ម៉ឺនតោន/១ឆ្នាំ បរិមាណនេះមានចំនួនស្មើនឹង៤.២-៥.៥ដង ធំជាងសមត្ថភាពចំរាញ់យករ៉ែ ដូចបានបញ្ជាក់នៅក្នុងឯកសាររបស់ក្រុមហ៊ុន។

**១៨៦.** ក្រោយពេលដំណើការអាជីវកម្មបានមួយរយៈពេលខ្លី (ពេលដែលពុំនូកអាចម៍រ៉ែមានបរិមាណប្រមាណ ៣០០០ម៣) ក្រុមហ៊ុនត្រូវសហការជាមួយក្រុមហ៊ុនឬស្ថាប័នជំនាញ ដើម្បីធ្វើការសិក្សាបន្ថែមទៅលើបញ្ហាទាំង៦ចំណុចដូចមានបញ្ជាក់នៅក្នុងភាពចាំបាច់នៃការវាយតំលៃបន្ថែម (Additional Impacts Assessment Requirement)។

**១៨៧.** ដើម្បីធានាបានថា ម្ចាស់គំរោងដើរតួរនាទីសំខាន់នៅក្នុងការគ្រប់គ្រងបរិស្ថាន ទៅតាមវិធានការណ៍នៃការគ្រប់គ្រងដូចបានលើកឡើងនៅក្នុង ផែនការគ្រប់គ្រងបរិស្ថាន (EMP) និងឬក៏អនុវត្តន៏តាមទាំងស្រុងជាមួយនឹងវិធានការណ៍កាត់បន្ថយផលប៉ះពាល់ ដូចមានបញ្ជាក់នៅក្នុងតារាង ៨-១ និង៨-៣ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ ចាំបាច់ត្រូវពិនិត្យការប្រតិបត្តិដោយយកចិត្តទុកដាក់ តាមរយៈការពិនិត្យតាមដានវាយតម្លៃជាប្រចាំលើការអនុវត្តន៏ប្រព័ន្ធ ក៏ដូចជាការងារផ្សេងៗទៀតដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថានផងដែរ។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១០

**នាយក**

**ហត្ថលេខា**

Green Consultancy Firm

KINGDOM OF CAMBODIA

**បណ្ឌិត លី សុពណ៌-មុនី**

ភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១០

**នាយកក្រុមហ៊ុន**

**ហត្ថលេខា**